**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ ក្រុមអ្នកជំនាញ អ.ស.ប ព្រួយបារម្ភយ៉ាងខ្លាំងចំពោះការឃុំខ្លួនក្មេងប្រុសម្នាក់ មានជំងឺអូទីស្សឹម ដែលបានរិះគន់តាមអនឡាញ

ទីក្រុងហ្សឺណែវ (២ កញ្ញា ២០២១) ក្រុមអ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប * នៅថ្ងៃនេះ បានអំពាវនាវសូមឱ្យកម្ពុជាដោះលែងក្មេងប្រុសម្នាក់អាយុ១៧ ឆ្នាំ ដែលមានជំងឺអូទីស្សឹម ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលជាងពីរខែមកហើយ ដោយមិនបានជួបគ្រួសារគាត់។

អនីតិជនរូបនេះ ដែលឳពុកគាត់ជាអតីតមន្ត្រីគណបក្សប្រឆាំង និងម្តាយគាត់ជាអ្នកការពារសិទ្ធិមនុស្ស ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៤ ខែមិថុនា និងត្រូវបានចោទប្រកាន់ពីបទញុះញង់ និងប្រមាថមន្ត្រីសាធារណៈពាក់ព័ន្ធនឹងសកម្មភាពតាមអនឡាញរបស់គាត់ ។ គាត់អាចប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់ពីរឆ្នាំ ប្រសិនជាគាត់ត្រូវបានផ្តន្ទាទោស។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា “ កុមារមានពិការភាពដែលត្រូវបានចោទប្រកាន់ពីបទរំលោភច្បាប់ គួរតែបានប្រព្រឹត្តស្របតាមគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ ហើយរាល់កិច្ចខិតខំប្រឹងប្រែង គួរតែត្រូវបានធ្វើឡើង ដើម្បីដាក់ពួកគាត់ឱ្យនៅក្រៅពន្ធនាគារ” ។ “ នេះជាការពិតជាពិសេស ក្នុងករណីមួយដូចជាករណីនេះ នៃការបញ្ចេញមតិដោយសេរី និងដោយសន្តិវិធី”។

“ អនុសញ្ញា អ.ស.ប ស្តីពីសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២ ចែងថាការចាប់ខ្លួន និងការឃុំខ្លួនកុមារ គួរតែត្រូវបានប្រើជាជម្រើសចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុតប៉ុណ្ណោះ។ អនុសញ្ញានេះ ការពារសិទ្ធិកុមារក្នុងការបញ្ចេញមតិ និងការចូលរួមផងដែរ។ យើងសូមជំរុញឱ្យអាជ្ញាធរកម្ពុជាទម្លាក់ការចោទប្រកាន់ និងដោះលែងអនីតិជនរូបនេះជាបន្ទាន់។”

អនីតិជននេះ ដែលមិនអាចត្រូវបានបង្ហាញអត្តសញ្ញាណជាសាធារណៈដោយសារតែអាយុរបស់គាត់ ត្រូវបានចាប់ខ្លួនដោយគ្មានដីកា ហើយក្រុមគ្រួសារគាត់មិនអាចជួបគាត់បាន ខណៈពេលដែលគាត់ត្រូវបាននគរបាលឃុំខ្លួន ឬចាប់តាំងពីពេលដែលគាត់ត្រូវបានចាប់ខ្លួន។ កន្លងមក គាត់ត្រូវបានបដិសេធការស្នើសុំឱ្យនៅក្រៅឃុំ។

នីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស មិនត្រឹមតែបានលើកឡើងករណីរបស់គាត់ជាមួយអាជ្ញាធរនៅក្នុងលិខិតឧបាស្រ័យរួមគ្នាមួយនោះទេ ប៉ុន្តែថែមទាំងនៅក្នុងកិច្ចប្រជុំទ្វេភាគីជាមួយមន្ត្រីរដ្ឋាភិបាលផងដែរ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា " នេះជាការគួរឱ្យព្រួយបារម្ភជាពិសេស ដោយសារអនុសញ្ញា អ.ស.ប ស្តីពីសិទ្ធិជនពិការ ដែលកម្ពុជាជាភាគីផងដែរនោះ តម្រូវឱ្យអាជ្ញាធរគិតគូរពីឧត្តមប្រយោជន៍របស់កុមារដែលមានពិការភាព និងផ្តល់ជំនួយសមស្រប " ។

" យើងមានការព្រួយបារម្ភខ្លាំងផងដែរដែលកុមាររូបនេះ ត្រូវបានគេសួរចម្លើយដោយគ្មានវត្តមានមេធាវី ឬអាណាព្យាបាលរបស់គាត់ ដែលរំលោភលើច្បាប់ស្តីពីយុត្តិធម៌អនីតិជនកម្ពុជា និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" ។

ឳពុករបស់អនីតិជនរូបនេះ ជាអតីតសមាជិកនៃគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ ត្រូវបានជាប់ពន្ធនាគារតាំងពីខែមិថុនា ឆ្នាំ២០២០ ។ ម្តាយគាត់ជាសមាជិកសកម្មនៃក្រុមអ្នកការពារសិទ្ធិមនុស្ស ដែលគេស្គាល់ថា ក្រុមស្ត្រីថ្ងៃសុក្រកម្ពុជា ត្រូវបានកងកម្លាំងសន្តិសុខវាយដំក្នុងអំឡុងពេលជួបជុំដោយសន្តិវិធី ទាមទារឱ្យមានការដោះលែងសមាជិកគណបក្សសង្គ្រោះជាតិ។ កាលពីខែមិថុនា មន្ត្រីសន្តិសុខខ័ណ្ឌបានរឹបអូសបដារបស់ពួកគាត់ដោយបំពាន នៅក្នុងអំឡុងពេលធ្វើបាតុកម្មមួយនៅខាងមុខការិយាល័យ OHCHR ប្រចាំកម្ពុជា។

ក្មេងប្រុសរូបនេះ ធ្លាប់ត្រូវបានចាប់ខ្លួនកាលពីលើកមុន ប៉ុន្តែមិនត្រូវបានចោទប្រកាន់ទេកាលនោះ ហើយក៏ធ្លាប់ត្រូវបានជនមិនស្គាល់មុខវាយដំផងដែរ។ បន្ទាប់ពីការចាប់ខ្លួនគាត់កាលពីខែតុលាឆ្នាំមុន នៅខាងមុខទីស្នាក់ការកណ្តាលចាស់នៃគណបក្សសង្គ្រោះជាតិ គាត់ត្រូវបានគេរាយការណ៍ថា ត្រូវបាននគរបាលដាល់ និងទះកំផ្លៀងគាត់ក្នុងអំឡុងពេលសួរចម្លើយ។ ពីរថ្ងៃក្រោយមក គាត់ត្រូវបានដោះលែងដោយគ្មានការចោទប្រកាន់។ នៅខែមេសាឆ្នាំនេះ គាត់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ដោយសារមានស្រាំឆ្អឹងលលាដ៍ក្បាល បន្ទាប់ពីបុរសពីរនាក់បានជិះម៉ូតូតាមវាយគាត់ដោយដុំឥដ្ឋ។

នៅឆ្នាំ២០១១ គណៈកម្មាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិកុមារ បានអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជា លើកកម្ពស់ "វិធានការជំនួសការឃុំខ្លួន" ចំពោះកុមារ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា " យើងសូមអំពាវនាវយ៉ាងទទូចដល់រដ្ឋាភិបាលកម្ពុជា ឱ្យដោះលែងកុមាររូបនេះ ហើយធានាថាសិទ្ធិមនុស្សរបស់គាត់ ត្រូវបានការពារស្របតាមគោលការណ៍ឧត្តមផលប្រយោជន៍របស់កុមារ ដោយអនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងច្បាប់កម្ពុជា" ។

**ចប់**

* **ក្រុមអ្នកជំនាញ៖ លោក វិទិត ម៉ុនតារបន (Mr. Vitit Muntarbhorn)** *អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា* **អ្នកស្រី អីរ៉េន ខាន់ (Ms. Irene Khan)** អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងទស្សនៈ **អ្នកស្រី ត្លាលេង ម៉ូហ្វូខេង (Ms. Tlaleng Mofokeng)** អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនគ្រប់រូបក្នុងការទទួលបានស្តង់ដារខ្ពស់បំផុតផ្នែកសុខភាពផ្លូវការនិងផ្លូវចិត្ត និង **អ្នកស្រី ម៉ារី ឡល័រ (Mary Lawlor)** *អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស។*

*អ្នករាយការណ៍ពិសេស គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃក្រុមអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលដោះស្រាយស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយៗជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ក្រុមអ្នកជំនាញនៃនីតិវិធីពិសេស ធ្វើការផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយមិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ខ្លួនឡើយ។ ពួកគេធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ។*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទង៖ លោក ម៉ាមូត ហ្គាកា (Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+ ៨៥៥ (0) ១២ ៧៩០ ១៧៨ ឬ តាមរយៈអ៊ីម៉ែល៖ mgarga@ohchr.org) ឬ លោក ណាវីដ អាមេត (Naveed Ahmad) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩៤៧៧ ឬ តាមរយៈអ៊ីម៉ែល៖ Nahmed@ohchr.org)*

*សម្រាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់អ.ស.ប សូមទាក់ទង៖ លោក ហ្សេរីមី ឡូរង់ស៍ (Jeremy Laurence) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៧៥៧៨) អ៊ីម៉ែល៖ jlaurence@ohchr.org)*

*តាមដានព័ត៌មានទាក់ទងនឹងក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់ អ.ស.ប តាមបណ្ដាញទ្វីធទ័រ Twitter@UN_SPExperts*

តើអ្នកខ្វល់អំពីពិភពលោកដែលយើងរស់នៅ ឬទេ?

**ដូច្នេះ ក្រោកឈរ ដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។**

#Standup4humanrights

ហើយចូលទៅកាន់គេហទំព័រ http://www.standup4humanrights.org